ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០

# សេចក្តីប្រកាសព័ត៌មាន

## អាល្លឺម៉ង់ចូលរួមវិភាគទានថវិកាចំនួន ១,២ លានអឺរ៉ូ ដល់ភាគីកម្ពុជានៃ អ.វ.ត.ក

រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់តាមរយៈអង្គការ GTZ បានចូលរួមវិភាគទានថវិកាចំនួន ១,២ លានអឺរ៉ូ ដល់គម្រោងបង្កើនការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក។ គម្រោងនេះត្រូវបានចុះហត្ថលេខាដោយនាយក GTZ ប្រចាំតំបន់ទទួលបន្ទុកអាស៊ីខាងត្បូង ឡាវ និងកម្ពុជា នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០ និងចុះហត្ថលេខាផងដែរដោយ ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អ.វ.ត.ក នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០។

វិភាគទាននេះផ្តល់ជូនសម្រាប់គម្រោងដែលមានរយៈពេល១៦ខែ ចាប់ផ្តើមអនុវត្តនៅខែកញ្ញា ឆ្នាំ២០១០ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១។ គម្រោងនេះនឹងគ្រោបសកម្មភាពនៃការដំណើរការ ការផ្សព្វផ្សាយ និងការតំណាងតាមផ្លូវច្បាប់នៅចំពោះមុខ អ.វ.ត.ក។ ការចូលរួមរបស់ជនរងគ្រោះគឺជាវិស័យមួយដែល អ.វ.ត.ក កំពុងបំបែកឯកត្តកកម្មនិងកំណត់ស្តង់ដាថ្មីសម្រាប់តុលាការដែលមានការគាំទ្រនិងចូលរួមពីអន្តរជាតិ។ គម្រោងនេះនឹងបន្តពង្រឹងយុត្តិធម៌និងការផ្សះផ្សាតាមរយៈការចូលរួមប្រកបដោយប្រសិទ្ធផលរបស់ជនរងគ្រោះនៅក្នុង អ.វ.ត.ក។

ប្រទេសអាល្លឺម៉ង់គឺជាម្ចាស់ជំនួយដ៏សំខាន់មួយនិងបាននឹងកំពុងគាំទ្រ អ.វ.ត.ក ចាប់តាំងពីការចាប់ផ្តើមដំបូងក្នុងឆ្នាំ២០០៦។ គិតមកដល់ពេលនេះ ប្រទេសអាល្លឺម៉ង់បានផ្តល់ជំនួយជាថវិកាចំនួន៧លានអឺរ៉ូសម្រាប់ភាគីអន្តរជាតិ និងភាគីជាតិនៃ អ.វ.ត.ក ចាប់តាំងពីឆ្នាំ២០០៥ មក។ នៅក្នុងឆ្នាំ២០១០ ក៏ដូចជាឆ្នាំ២០០៩ មួយឆ្នាំៗ ប្រទេសអាល្លឺម៉ង់បានផ្តល់ថវិកាចំនួន ១,៥ លានអឺរ៉ូ ដល់ អ.វ.ត.ក។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**រាជ សម្បត្តិ**
ប្រធានកិច្ចការសាធារណៈ អ.ត.ត.ក
ទូរស័ព្ទចល័ត៖ +៨៥៥-១២ ៤៨៨ ១៥៦
ទូរសារ៖ +៨៥៥-២៣ ២១៩ ៨៤១
អ៊ីម៉ែល៖ reach.sambath@eccc.gov.kh

**ឌីម សុវណ្ណារុំ**
មន្ត្រីព័ត៌មាន អ.វ.ត.ក
ទូរស័ព្ទ៖ +៨៥៥-១២ ៤៨៨ ០៩៤
ទូរសារ៖ +៨៥៥-២៣ ២១៩ ៨៤១
អ៊ីម៉ែល៖ dim.sovannarom@eccc.gov.kh

Yuko Maeda
មន្ត្រីទំនាក់ទំនងសាធារណៈ អ.វ.ត.ក
ទូរស័ព្ទ៖ +៨៥៥-១២ ៤៨៨ ០២៣
ទូរស័ព្ទអចល័ត៖ +៨៥៥-២៣ ២១៩ ៨៤១ ext.6139
អ៊ីម៉ែល៖ maeday@un.org